ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌ
លេខ ២០៩០ អក
ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌ
លេខ ៧១ "ផ.ក្រ"
ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០៨៖៣០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាប្រធានក្រុមប្រឹក្សា
លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារង នៃសាលាដំបូងខេត្តកណ្ដាល

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២០៩០ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្ដាល ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សុវណ្ណារីន ភេទប្រុស អាយុ ១៥ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិកណ្ដាល ឃុំរលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុណ្ណារិទ្ធ "រស់" ម្ដាយឈ្មោះ [redacted] ដាលីន "រស់" ជាអនីតិជន ទោសពីមុន គ្មាន (ក្រៅឃុំ) ។

២-ឈ្មោះ [redacted] រីន ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតនៅភូ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិកណ្ដាល ឃុំរលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] រឿន "រស់" ម្ដាយឈ្មោ [redacted] ស៊ីថា "រស់" ជាអនីតិជន ទោសពីមុន គ្មាន (ក្រៅឃុំ) ។

ដោយមានលោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឱ្យស្លាប់អ្នកដទៃ ប្រព្រឹត្តនៅចំណុចភូមិថ្មីទី១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។៚



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ជា ភេទប្រុស អាយុ ៥៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិប្រជុំអង្គ ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

**ដោយមានលោកស្រីមេធាវី [redacted] ជាមេធាវីតំណាង ។**

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង១១ និង ៣០នាទី ស្ថិតនៅចំណុចភូមិថ្មី១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល មានករណី **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឱ្យស្លាប់អ្នកដទៃ** ដោយមុនពេលកើតហេតុមានម៉ូតូមួយគ្រឿងម៉ាក HONDA DREAM 125 ពណ៌ខ្មៅ ពាក់ស្លាកលេខ 1BB-7281 បើកបរដោយឈ្មោះ[redacted] **ឌីណា** ភេទប្រុស អាយុ២៣ឆ្នាំ ទិសដៅពីត្បូងទៅជើង ពេលបើកបរមកដល់ចំណុចកើតហេតុខាងលើ ក៏បានវេចង្កូតមកឆ្វេងដៃ បុកជាមួយម៉ូតូមួយគ្រឿងម៉ាក HONDA DREAM 125ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1DH-0593 បើកបរដោយឈ្មោះ[redacted] **វីន** ភេទប្រុស អាយុ១៧ឆ្នាំ ជិះពីក្រោយឈ្មោះ [redacted] **សុវណ្ណារីន** ភេទប្រុស ក្នុងទិសដៅពីជើងមកត្បូង (ផ្ទុយគ្នា) បណ្តាលឱ្យឈ្មោះ[redacted] **ឌីណា** ស្លាប់ពេលទៅដល់មន្ទីរពេទ្យ ហើយឈ្មោះ[redacted] **វីន** និងឈ្មោះ[redacted]**សុវណ្ណារីន** រងរបួស ។

-**បានឃើញ** របាយការណ៍បូកសរុបលេខ ១២២ របក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក នៃស្នងការនគរបាលខេត្តកណ្តាល ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **១៥៨ ដកសស** ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **៥១៨ ដកសព** ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ **៥៦៣ ដកដស** ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណារីន** បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខ្លួនបានចេញពីប្រឡងឌីប្លូមនៅសាលាវិទ្យាល័យ ហ៊ុន សែន សេរីភាព ហើយបានជិះម៉ូតូជាមួយមិត្តឈ្មោះ [redacted] **វីន** ចេញពីសាលាសំដៅទៅផ្ទះ បើកបរក្នុងទិសដៅពីជើងទៅត្បូងក្នុងល្បឿនប្រហែល២៥គីឡូម៉ែត្រក្នុងមួយម៉ោង លុះមកដល់ចំណុចកើតហេតុស្ថិតនៅទល់មុខមន្ទីរពេទ្យពិសិដ្ឋ ក្នុងភូមិថ្មី១ ក៏ឃើញមានម៉ូតូមួយគ្រឿង បើកបរដោយមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះក្នុងទិសដៅផ្ទុយគ្នាក្នុងល្បឿនលឿន ហើយជិះវ៉ាឡានស្រាប់តែរអកសើជាមួយម៉ូតូមួយគ្រឿងទៀត ហើយគាត់បានជៀសម៉ូតូ

នោះ តែពេលជៀសគឺធ្វើឱ្យម៉ូតូដួលរមៀលមកត្រូវជាមួយម៉ូតូខ្លួនធ្វើឱ្យម៉ូតូខ្លួនដួល ។ សំណូមពរ សុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ ។

**-ជនជាប់ចោទឈ្មោះ** [redacted] **រីន** បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខ្លួនបានជិះម៉ូតូមួយគ្រឿងស៊េរីឆ្នាំ២០១៥ ឌុបមិត្តភក្តិឈ្មោះ [redacted] **សុវណ្ណារីន** ចេញពីប្រឡងឌីប្លូមនៅសាលាវិទ្យាល័យ ហ៊ុន សែន សេរីភាព បើកបរក្នុងទិសដៅពីជើងទៅត្បូងក្នុងល្បឿនប្រហែល ២៥គីឡូម៉ែត្រក្នុងមួយម៉ោង លុះមកដល់ចំណុចកើតហេតុស្ថិតនៅទល់មុខមន្ទីពេទ្យពិសិដ្ឋ ក្នុងភូមិថ្មី ១ ក៏ឃើញមានម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីមស៊េរី២០១១ បើកបរដោយមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ ជិះក្នុងទិសដៅផ្ទុយគ្នាក្នុងល្បឿនលឿន ហើយជិះវ៉ាឡានស្រាប់តែអកសើជាមួយម៉ូតូមួយគ្រឿងទៀត ហើយគាត់បានជៀសម៉ូតូនោះ តែពេលជៀស គឺធ្វើឱ្យម៉ូតូដួលរមៀលមកត្រូវជាមួយម៉ូតូខ្លួនធ្វើឱ្យម៉ូតូខ្លួនដួល ។ ពួកខ្លួនមិនមានពាក់មួកសុវត្ថិភាពទេ។សំណូមពរសុំឱ្យតុលាការសម្រេចលើកលែងការចោទប្រកាន់ដល់ខ្លួន ។

-ឈ្មោះ [redacted] **ប៊ុណ្ណារិទ្ធ** បានឆ្លើយថា ខ្លួនត្រូវជាឪពុករបស់ឈ្មោះ [redacted] **សុវណ្ណារីន** ចំណែកឈ្មោះ [redacted] **រីន** គឺមិនមែនជាកូនរបស់ខ្លួនទេ តែគាត់បានមកនៅជាមួយខ្លួនតាំងពីឆ្នាំ២០១៩ ហើយគាត់មិនមានប័ណ្ណបើកបរទេ ។

-លោកស្រីមេធាវី [redacted] មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានថា៖ នៅថ្ងៃកើតហេតុគឺពិតជាមានអង្គហេតុដូចការចោទប្រកាន់មែន សុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំទាមទារសំណងចំនួន ៣,០០០ដុល្លារអាមេរិក ។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា** ៖ នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] ឌីណា បានបើកម៉ូតូមួយគ្រឿងម៉ាក HONDA DREAM 125 ពណ៌ខ្មៅ ពាក់ស្លាកលេខ 1BB-7281 ក្នុងល្បឿនលឿនក្នុងទិសដៅផ្ទុយគ្នាជាមួយម៉ូតូម៉ាក HONDA DREAM 125ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1DH-0593 បើកបរដោយជនជាប់ចោទឈ្មោះ [redacted] **រីន** ដោយមានជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណារីន** ជិះពីក្រោយ ស្រាប់តែមកដល់កន្លែងកើតហេតុ ឈ្មោះ [redacted] ឌីណា បានវេរចង្កូតចូលគន្លងផ្លូវរបស់ជនជាប់ចោទទាំងពីរទើបបណ្តាលឱ្យបុកគ្នា ។ ហេតុនេះ ស្នើសុំឱ្យតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

-លោកស្រីមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា៖ នៅថ្ងៃកើតហេតុជនរងគ្រោះបានបើកម៉ូតូក្នុងល្បឿនលឿនហើយបានវេរចង្កូតចូលក្នុងគន្លងផ្លូវរបស់កូនក្តីខ្លួន ដែលបញ្ជាក់ឱ្យឃើញថា កូនក្តីខ្លួនឈ្មោះ [redacted] **រីន** មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដោយឡែកកូនក្តីខ្លួនឈ្មោះ [redacted] **សុវណ្ណារីន** គឺគ្រាន់តែជាអ្នកជិះពីក្រោយប៉ុណ្ណោះ ។ សំណូមពរ សុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនទាំងពីររួចផុតពីបទចោទ តាមមាត្រា ៤៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។៚



Scanned with CamScanner

ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់មេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង១១ និង ៣០នាទី ស្ថិតនៅចំណុចភូមិថ្មី១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល មានករណី **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្ដាលឲ្យស្លាប់អ្នកដទៃ** ដោយមុនពេលកើតហេតុមានម៉ូតូមួយគ្រឿងម៉ាក HONDA DREAM 125 ពណ៌ខ្មៅ ពាក់ស្លាកលេខ 1BB-7281 បើកបរដោយឈ្មោះ [redacted] **ឌីណា** ភេទប្រុស អាយុ២៣ឆ្នាំ ទិសដៅពីត្បូងទៅជើងពេលបើកបរមកដល់ចំណុចកើតហេតុខាងលើក៏បានវេជង្កូតមកឆ្វេងដៃបុកជាមួយម៉ូតូមួយគ្រឿងម៉ាក HONDA DREAM 125ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1DH-0593 បើកបរដោយឈ្មោះ [redacted] **រីន** ភេទប្រុស អាយុ១៧ឆ្នាំ ជិះពីក្រោយឈ្មោះ [redacted] **សុវណ្ណារីន** ភេទប្រុស ក្នុងទិសដៅពីជើងមកត្បូង (ផ្ទុយគ្នា) បណ្ដាលឲ្យឈ្មោះ [redacted] **ឌីណា** ស្លាប់ពេលទៅដល់មន្ទីរពេទ្យ ហើយឈ្មោះ [redacted] **រីន** និងឈ្មោះ [redacted] **សុវណ្ណារីន** រងរបួស ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណារីន** និងឈ្មោះ [redacted] **រីន** បានឆ្លើយប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខ្លួនបានចេញពីប្រឡងឌីប្លូមនៅសាលាវិទ្យាល័យ ហ៊ុន សែន សេរីភាព ហើយបានជិះម៉ូតូជាមួយគ្នា ដោយមានឈ្មោះ [redacted] **រីន** ជាអ្នកបើកបរម៉ូតូ ចេញពីសាលាសំដៅទៅផ្ទះ បើកបរក្នុងទិសដៅពីជើងទៅត្បូងក្នុងល្បឿនប្រហែល ២៥ គីឡូម៉ែត្រក្នុងមួយម៉ោង លុះមកដល់ចំណុចកើតហេតុស្ថិតនៅទល់មុខមន្ទីពេទ្យពិសិដ្ឋ ក្នុងភូមិថ្មី១ ក៏ឃើញមានម៉ូតូមួយគ្រឿង បើកបរដោយមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះក្នុងទិសដៅផ្ទុយគ្នាក្នុងល្បឿនលឿន ហើយជិះវ៉ាឡានស្រាប់តែអកសើជាមួយម៉ូតូមួយគ្រឿងទៀត ហើយគាត់បានជៀសម៉ូតូនោះ តែពេលជៀស**គឺធ្វើឲ្យម៉ូតូដួលរមៀលមកត្រូវជាមួយម៉ូតូខ្លួនធ្វើឲ្យម៉ូតូខ្លួនដួល** ។

តុលាការយល់ឃើញថា ចម្លើយនេះគឺជាចម្លើយត្រឹមត្រូវ ដោយហេតុថា ចម្លើយនេះគឺស៊ីសង្វាក់នឹងការសន្និដ្ឋានរបស់សមត្ថកិច្ចដែលបានចុះទៅធ្វើការពិនិត្យនិងវាស់វែងនៅកន្លែងកើតហេតុថា ឈ្មោះ [redacted] **ឌីណា** គឺពិតជាបានបើកបរម៉ូតូក្នុងល្បឿនលឿន ចូលចំណែកផ្លូវយានម្ខាងទៀតដែលមានទិញដៅផ្ទុយគ្នា ប្រាកដមែន ។



Scanned with CamScanner

ម្យ៉ាងវិញទៀត យោងតាមសំបុត្របញ្ជាក់កំណើតលេខ ២៤៤ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ គឺបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] រីន គឺកើតនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៤ បើគិតមកដល់ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ជាថ្ងៃកើតហេតុ ជនជាប់ចោទឈ្មោះ [redacted] រីន មានអាយុ ១៧ឆ្នាំ៤ខែ២០ថ្ងៃ ហើយម៉ូតូដែលជនជាប់ចោទឈ្មោះ [redacted] រីន បើកបរនៅថ្ងៃកើតហេតុ គឺម៉ាក HONDA DREAM 125 ដែលយោងតាម មាត្រា ៨ថ្មី នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក គឺមិនតម្រូវឲ្យអ្នកបើកបរមានប័ណ្ណបើកបរឡើយ ។ ដោយឡែក ចំពោះជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារីន គឺគ្រាន់តែជាអ្នកជិះម៉ូតូពីក្រោយឈ្មោះ [redacted] រីន ប៉ុណ្ណោះ ។

តុលាការយល់ឃើញថា គ្រោះថ្នាក់ចរាចរណ៍នេះកើតឡើងគឺមិនមែនជាកំហុសរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារីន និងឈ្មោះ [redacted] រីន ទេ ។ មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារីន និងឈ្មោះ [redacted] រីន ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យស្លាប់អ្នកដទៃ** ឡើយ ហេតុនេះគប្បីតុលាការសម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារីន និងឈ្មោះ [redacted] រីន រួចខ្លួនពីបទចោទពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅភូមិថ្មីទី១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក តាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-លោកស្រីមេធាវី [redacted] មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានថា នៅថ្ងៃកើតហេតុគឺពិតជាមានអង្គហេតុដូចការចោទប្រកាន់មែន សុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំទាមទារសំណងចំនួន ៣,០០០ដុល្លារអាមេរិក ។ តុលាការយល់ឃើញថា ការសន្និដ្ឋាននេះមិនមានលក្ខណៈត្រឹមត្រូវអង្គហេតុនៃរឿងទេ ផ្អែកតាមការយល់ឃើញខាងលើ ហេតុនេះគប្បីតុលាការមិនលើកយកការសន្និដ្ឋាននេះមកពិចារណាឡើយ ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] ឌីណា បានបើកម៉ូតូមួយគ្រឿងម៉ាក HONDA DREAM 125 ពណ៌ខ្មៅ ពាក់ស្លាកលេខ 1BB-7281 ក្នុងល្បឿនលឿនក្នុងទិសដៅផ្ទុយគ្នាជាមួយម៉ូតូម៉ាក HONDA DREAM 125ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1DH-0593 បើកបរដោយជនជាប់ចោទឈ្មោះ [redacted] រីន ដោយមានជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារីន ជិះពីក្រោយស្រាប់តែមកដល់កន្លែងកើតហេតុ ឈ្មោះ [redacted] ឌីណា បានវេរចង្កូតចូលគន្លងផ្លូវរបស់ជនជាប់ចោទទាំងពីរ ទើបបណ្តាលឲ្យបុកគ្នា ហេតុនេះស្នើសុំឲ្យតុលាការពិចារណា និងសម្រេចតាមច្បាប់ គប្បីតុលាការពិចារណា ។

៥-លោកស្រីមេធាវី [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានថា នៅថ្ងៃកើតហេតុជនរងគ្រោះបានបើកម៉ូតូក្នុងល្បឿនលឿនហើយបានវេរចង្កូតចូលក្នុងគន្លងផ្លូវរបស់កូនក្តីខ្លួន ដែលបញ្ជាក់ឲ្យឃើញថា កូនក្តីខ្លួនឈ្មោះ [redacted] រីន មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដោយឡែកកូនក្តីខ្លួនឈ្មោះ [redacted]



Scanned with CamScanner

សុវណ្ណារីន គឺគ្រាន់តែជាអ្នកជិះពីក្រោយប៉ុណ្ណោះ ។ សំណូមពរ សុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនទាំងពីររួចផុតពីបទចោទ តាមមាត្រា ៤៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។ ឃើញថា ការសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវ ផ្អែកតាមការយល់ឃើញខាងលើ គប្បីតុលាការពិចារណា ។

៦-វត្ថុតាងរួមមាន៖ ម៉ូតូម៉ាក HONDA DREAM 125 ពណ៌ខ្មៅ ពាក់ស្លាកលេខ 1BB-7281 ចំនួន ០១គ្រឿង និងម៉ូតូម៉ាក HONDA DREAM 125ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1DH-0593 ចំនួន ០១ គ្រឿង គប្បីតុលាការពិចារណា និងសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ ។

## ហេតុដូច្នេះ សម្រេច

១-ឱ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារីន និងឈ្មោះ [redacted] រីន រួចខ្លួនពីបទចោទ ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅភូមិថ្មីទី១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក តាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-វត្ថុតាងរួមមាន៖ ម៉ូតូម៉ាក HONDA DREAM 125 ពណ៌ខ្មៅ ពាក់ស្លាកលេខ 1BB-7281 ចំនួន ០១គ្រឿង និងម៉ូតូម៉ាក HONDA DREAM 125ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1DH-0593 ចំនួន ០១ គ្រឿង **ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ** ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារីន និងឈ្មោះ [redacted] រីន ចំពោះមុខមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជា និងប្រកាសជាសាធារណៈ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងច្បាប់កំណត់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សាជំនុំជម្រះ** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្តាល,ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner